ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ........១៤៧/២០..........ក.ប/ស.ណ.ន ប.ស.ន

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធក្នុងបេឡាជាតិសន្តិសុខសង្គម ដើម្បីទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាល

អនុលោមតាមប្រកាសអន្តរក្រសួងលេខ ៤០៤កប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងដើម្បីធានាបាននូវប្រសិទ្ធភាព និងតម្លាភាព ក្នុងការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** សូមធ្វើការណែនាំដល់លោក/លោកស្រីប្រធាន សមាគម ឬ អង្គការវិជ្ជាជីវៈ ដែលគ្រប់គ្រងកម្មករនិយោជិតក្រៅប្រព័ន្ធទាំងអស់ជ្រាបថា ដើម្បីចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធក្នុងបេឡាជាតិសន្តិសុខសង្គម(**ប.ស.ស.**) សមាគម ឬ អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតក្រៅប្រព័ន្ធទាំងអស់ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ចំពោះសមាគម ត្រូវមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងមហាផ្ទៃ
- ចំពោះអង្គការវិជ្ជាជីវៈត្រូវមានវិញ្ញាបនប័ត្រចុះបញ្ជីអង្គការវិជ្ជាជីវៈចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធដែលជាសមាជិករបស់សមាគម ឬ អង្គការវិជ្ជាជីវៈត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតបញ្ជាក់អំពីមុខរបរនិងទីលំនៅបច្ចុប្បន្នដែលចេញដោយអាជ្ញាធររាជធានីខេត្តតាមនីតិវិធី។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជម្រាបជូនសាធារណជនទាំងអស់ជ្រាបថា ការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលដោយ **ប.ស.ស.** មិនតម្រូវឲ្យមានការបង់កម្រៃសេវាឡើយ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា លោក/លោកស្រីប្រធានសមាគម ឬ អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតក្រៅប្រព័ន្ធនឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ ចន្ទ ៧រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០២០
រដ្ឋមន្ត្រី

អ៊ិត សំហេង

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៥